# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ០១ សសរ**

## សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការអន្តរក្រសួងរៀបចំបណ្ឌានគតិយុត្ត និងនីតិវិធីស្តីពីការប្រើប្រាស់ដីធ្លី នៅខេត្ត ក្រុង និងទីប្រជុំជន នៃព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៤/នស/៩៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន


www.pheakdeylaw.com

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងរៀបចំ ដែនដី នគរូបនីយកម្ម និង សំណង់
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## ស ម្រេ ច

**ប្រការ ១ :** ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួងរៀបចំបទដ្ឋានគតិយុត្តនិងនីតិវិធីស្តីពីការប្រើប្រាស់ដីធ្លី នៅខេត្ត ក្រុង និងទីប្រជុំជន នៃព្រះរាជាណាចក្រកម្ពុជា ដែលមានសមាសភាព ដូចខាងក្រោម :

| | | |
|---|---|---|
| ១. ឯកឧត្តម **អ៊ឹម ឈុនលឹម** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ជាប្រធាន |
| ២. ឯកឧត្តម **ព្រំ សុខា** | រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | ជាអនុប្រធាន |
| ៣. ឯកឧត្តម **នុត ណារ៉ាង** | រដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ជាអនុប្រធាន |
| ៤. ឯកឧត្តម **តៀង សុភ័ណ្ឌ** | រដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ជាសមាជិក |
| ៥. ឯកឧត្តម **កែច ខេម៉ា** | រដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ជាសមាជិក |
| ៦. ឯកឧត្តម **អ៊ូ ម៉ុនឡុង** | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| ៧. ឯកឧត្តម **លឹម សុគុន** | រដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ជាសមាជិក |
| ៨. ឯកឧត្តម **យិន គឹមស៊ាន** | រដ្ឋលេខាធិការ ក្រសួងបរិស្ថាន | ជាសមាជិក |
| ៩. ឯកឧត្តម **លី ប្រួស** | រដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ | ជាសមាជិក |
| ១០. ឯកឧត្តម **ត្រាំ អ៊ីវតឹក** | រដ្ឋលេខាធិការ ក្រសួងសាធារណៈការ និងដឹកជញ្ជូន | ជាសមាជិក |
| ១១. ឯកឧត្តម **សំ សារិត** | រដ្ឋលេខាធិការ ក្រសួងធនធានទឹក និងឧតុនិយម | ជាសមាជិក |

www.pheakdeylaw.com

១២. ឯកឧត្តម **ហ៊ុល លឹម** រដ្ឋលេខាធិការ ក្រសួងផែនការ ជាសមាជិក

១៣. ឯកឧត្តម **ឌុច ទននិត្យ** អគ្គនាយក នៃអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាសមាជិកអចិន្ត្រៃយ៍

១៤. លោក **តឹកកេត សំរេច** ជំនួយការឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិក។

**ប្រការ ២ :** គណៈកម្មការនេះមានភារកិច្ចរៀបចំបទដ្ឋានគតិយុត្ត និងនីតិវិធីស្តីពីការប្រើប្រាស់ដីធ្លី នៅខេត្ត ក្រុង និង ទីប្រជុំជន នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច។

**ប្រការ ៣ :** គណៈកម្មការនេះមានលេខាធិការដ្ឋានជាជំនួយការមួយ មានទីតាំងក្នុងទីស្តីការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលមានសមាសភាពដូចខាងក្រោម :

១. ឯកឧត្តម **ឌុច ទននិត្យ** អគ្គនាយក នៃអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាប្រធាន

២. លោក **ម៉េងហុង សុជាតិខេមរ៉ូ** អគ្គនាយករង នៃអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាសមាជិក

៣. លោក **ហាន់ វុទ្ធីណ្ណាត់** អគ្គនាយករង នៃអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាសមាជិក

៤. លោកស្រី **សួស សុផល** អគ្គនាយករង នៃអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាសមាជិក

៥. លោក **ម៉ែន សុផល** ប្រធាននាយកដ្ឋាននគរូបនីយកម្មនៃ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាសមាជិក

៦. លោក **ឡោក់ អន្តារ៉ា** ប្រធាននាយកដ្ឋានស្រាវជ្រាវ និងបទប្បញ្ញត្តិ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាសមាជិក។

លេខាធិការដ្ឋាននេះមានភារកិច្ចដូចខាងក្រោម :

- ស្រាវជ្រាវច្បាប់ និងឯកសារនានា ដើម្បីគាំទ្រផ្នែកបច្ចេកទេសក្នុងការរៀបចំបទដ្ឋានគតិយុត្ត និងនីតិវិធីស្តីពីការប្រើប្រាស់ដីធ្លី នៅខេត្ត ក្រុង និងទីប្រជុំជន នៃព្រះរាជាណាចក្រកម្ពុជា
- រៀបចំឯកសារ និងរបាយការណ៍បច្ចេកទេសឆ្លងកិច្ចប្រជុំគណៈកម្មការអន្តរក្រសួង
- រៀបចំសេចក្តីព្រាងរបាយការណ៍ឆ្លងកិច្ចប្រជុំគណៈកម្មការអន្តរក្រសួងដើម្បីពិនិត្យ និងសម្រេច ។

លេខាធិការដ្ឋាននេះ អាចប្រើប្រាស់មន្ត្រី នៃអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម និង អង្គភាពផ្សេងទៀត នៃក្រសួងរៀបចំ ដែនដី នគរូបនីយកម្ម និង សំណង់ ឱ្យជួយការងារតាមការចាំបាច់ ។

**ប្រការ ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ ១ និងប្រការ ៣ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ២០០៨

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល :***

*- ក្រសួងព្រះបរមរាជវាំង*

*- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*

*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*

*- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*

*- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*

*- ដូចប្រការ ៤*

*- រាជកិច្ច*

*- ឯកសារ-កាលប្បវត្តិ*

www.pheakdeylaw.com